ការពង្រឹង សមត្ថភាព

ការផ្សាយលើកទីពីរ

# កម្រងព័ត៌មានរបស់ចៃកា (JICA) ប្រចាំអគ្គនាយកដ្ឋានពន្ធដារ(អពដ)

ខែមេសា ឆ្នាំ២០១៣

## មាតិកា


ឧបករណ៍សំខាន់ក្នុងជីវិត "ការត្រិះរិះពិចារណា" ២

បដារគឺជាសម្ភារៈទំនាក់ទំនងសាធារណៈដែលមានប្រសិទ្ធិភាពថ្លៃចំណាយបំផុត ៣

កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន ៣

"ចំណេញដុល" គឺជាសញ្ញានៃហានិភ័យរបស់អ្នកជាប់ពន្ធ ៤

កិច្ចខិតខំប្រឹងប្រែងរបស់អពដរួមជាមួយកំណើនអាជីវកម្ម ៥

ព្រឹត្តិការណ៍ថ្មីៗ និងការងារកំពុងដំណើការ ៥


## ព្រឹត្តិការណ៍សំខាន់ៗ

- ការត្រឹះរិះពិចារណាគឺជាដំណើរការដ៏ឆ្លាតវៃក្នុងការវិភាគដោយសមហេតុដើម្បីពន្យល់អំពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយមូលហេតុត្រឹមត្រូវ
- កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន៖ តម្រូវការពិន្ទុភាសាអង់គ្លេសដែលត្រៀមសម្រាប់ការបើកឲ្យដាក់ពាក្យសុំនៅខែមិថុនា
- ការស្ទង់មតិការពេញចិត្តរបស់អ្នកជាប់ពន្ធ ត្រូវបានរៀបចំឡើងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងការឆ្លើយតបរបស់អ្នកជាប់ពន្ធ

## វគ្គនាការអំពីកម្មវិធីគម្រោង

បន្ទាប់ពីបេសកកម្ម Otake ដ៏ជោគជ័យដែលផ្តល់ឱកាសឲ្យមានការចែករំលែកគំនិតយោបល់អំពីការដោះស្រាយបញ្ហានោះ កម្មវិធីទីពីរនៅក្នុងកម្រងព័ត៌មានដែលលើកឡើងអំពី "ការត្រិះរិះពិចារណា៖ ការត្រួតពិនិត្យលើរដ្ឋបាលសារពើពន្ធ" ត្រូវបានរៀបចំឡើងនៅក្នុងខែមករា ឆ្នាំ២០១៣ ដោយសាស្ត្រាចារ្យជាន់ខ្ពស់មកពីប្រទេសជប៉ុន។ សិក្ខាសាលានេះបានផ្តល់ឲ្យសិក្ខាកាមនូវសមត្ថភាពក្នុងការវិភាគបញ្ហាប្រកបដោយភាពសមហេតុផល ដើម្បីជំនះរាល់បញ្ហាប្រឈមនានា។ ផ្នែកទី ២ នៅក្នុងកម្រងព័ត៌មាននេះ រួមបញ្ចូលនូវករណីសិក្សាជាក់ស្តែងមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលអាចឲ្យសិក្ខាកាម ប្រើប្រាស់ទស្សនាទានដែលបានសិក្សារួចដើម្បីស្វែងរកដំណោះស្រាយ។ សិក្ខាសាលានេះ បានរៀបចំឡើងរយៈពេលពីរសប្តាហ៍នៅចុងខែមីនា ដោយសាស្ត្រាចារ្យដដែលនៅក្នុងតំបន់ចំនួនបី។

វគ្គបណ្តុះបណ្តាលតាមតំបន់ចំនួនពីរ ត្រូវបានរៀបចំឡើងនៅក្នុងខែមករា។ ជាមួយគ្នានេះផងដែរ សាស្ត្រាចារ្យមកពី NTA និង NTC ប្រទេសជប៉ុន បានផ្តល់នូវសិក្ខាសាលាដើម្បីពិភាក្សាអំពីការបង្កើតសម្ភារៈទំនាក់ទំនងសាធារណៈដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលមួយសម្រាប់សវនកម្មសារពើពន្ធផងដែរ។ កម្មវិធីទាំងនេះគឺសុទ្ធតែមានលក្ខណៈជាការអនុវត្តជាក់ស្តែង ហើយចំណេះដឹងដែលទទួលបាន អាចកាន់តែមានប្រសិទ្ធភាពនៅពេលប្រើប្រាស់ដោយមានមូលដ្ឋាននៃ "ការត្រិះរិះពិចារណា"។

## អាទិភាពនៃការបង្កើតមជ្ឈមណ្ឌលប្រតិបត្តិការទិន្នន័យ និងមជ្ឈមណ្ឌលផ្តល់សេវាកម្មរបស់អគ្គនាយកពន្ធដារ

### ទស្សនកិច្ចសិក្សា មជ្ឈមណ្ឌលប្រតិបត្តិការទិន្នន័យ

នាយកដ្ឋានចំណូលនៃប្រទេសថៃ

ថ្ងៃទី០៤-០៥ ខែមីនា

ប្រទេសថៃមានគោលបំណងផ្លាស់ប្តូរ *"ដំណើរការការងារ គោលនយោបាយ ប្រតិបត្តិការ និងទស្សនៈរបស់មន្ត្រីពន្ធដារ"* ហើយលើកកម្ពស់ *"គុណភាពការងារ"*។

**ឯកឧត្តម អគ្គនាយក គង់ វិបុល បានដឹកនាំគណៈប្រតិភូទៅប្រទេសថៃ ក្នុងកិច្ចរៀបចំមជ្ឈមណ្ឌលប្រតិបត្តិការទិន្នន័យ (DPC) និងមជ្ឈមណ្ឌលផ្តល់សេវាកម្មរបស់អពដ។**

ការបញ្ចូល និងការផ្ទៀងផ្ទាត់ទិន្នន័យនៅមជ្ឈមណ្ឌលទិន្នន័យកណ្តាល និងការឆ្លើយតបនឹងសំណួររបស់អ្នកជាប់ពន្ធនៅមជ្ឈមណ្ឌលផ្តល់សេវាកម្ម ត្រូវបានបែងចែកទៅខាងក្រៅ ដើម្បីកាត់បន្ថយថ្លៃចំណាយ និងអនុញ្ញាតឲ្យមានការគ្រប់គ្រងបុគ្គលិកប្រកបដោយភាពបត់បែន។ រាល់ការងារការិយាល័យទាំងអស់ ត្រូវបានវាយតម្លៃដោយសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) និងពិនិត្យមើលឡើងវិញដោយជាទៀងរាល់ឆ្នាំដើម្បីលើកកម្ពស់ប្រសិទ្ធផល និងស្តង់ដារសេវាកម្ម។



បុគ្គលិកមួយរូបផ្ទៀងផ្ទាត់លិខិតប្រកាសពន្ធចំនួន ៣០០ ក្នុងមួយម៉ោង ហើយលិខិតប្រកាសពន្ធនីមួយៗត្រូវផ្ទៀងផ្ទាត់ដោយមនុស្ស

## ឧបករណ៍សំខាន់ក្នុងជីវិត "ការត្រិះរិះពិចារណា"

### សិក្ខាសាលាស្តីពី ការត្រិះរិះពិចារណា

ការត្រួតពិនិត្យលើរដ្ឋបាលសារពើពន្ធ

ថ្ងៃទី០៨-១១ ខែមករា

**ជាមូលដ្ឋាន ត្រូវស្វែងយល់អំពីឃ្លាមួយគឺ "របៀបចាប់ត្រី" មិនមែន "ត្រី" តែឯងនោះទេ**

មានមន្ត្រីពន្ធដារមួយរយនាក់ រួមទាំងប្រធានដែលមកពីសាខាពន្ធដារផ្សេងៗ បានចូលរួមក្នុងសិក្ខាសាលានេះ។ លោក Kodera គណនេយ្យករផ្នែក ពន្ធសាធារណៈដែលមានការទទួលស្គាល់ និងលោក Ishiguro សហការីសាស្ត្រាចារ្យសាកលវិទ្យាល័យ JOBU ប្រទេសជប៉ុន ដែលសុទ្ធតែជាអតីតមន្ត្រីពន្ធដារនៃ NTA បានជួយសម្របសម្រួលដល់កិច្ចពិភាក្សានេះ។ ការត្រិះរិះពិចារណាគឺជាដំណើរការដ៏ឆ្លាតវៃក្នុងការវិភាគដោយសមហេតុផល ដើម្បីពន្យល់អំពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយមូលហេតុត្រឹមត្រូវ។ សិក្ខាកាម បានរកឃើញថាជាការធ្វើឲ្យរាល់វិធានសារពើពន្ធទាំងអស់មានតម្លាភាពគឺជាប្រការសំខាន់ ដើម្បីសម្រេចឲ្យបាននូវសារពើពន្ធស្មើភាពមួយ និងលើកកម្ពស់ការអនុវត្តតាមរបស់អ្នកជាប់ពន្ធ





សុន្ទរកថាបើករបស់ឯកឧត្តមគឹម សុភ័ក្រ្ត ចំពោះការត្រិះរិះពិចារណា

## គម្រោងមានវិសាលភាពបន្តទៅព្រំដែនវៀតណាម

### ការបណ្តុះបណ្តាលនៅស្វាយរៀង

ថ្ងៃទី១៧-១៨ ខែមករា

**អាទិភាពរបស់មន្ត្រីពន្ធដារក្នុងការកែលម្អសេវាអ្នកជាប់ពន្ធ។** មន្ត្រីពន្ធដារសរុបចំនួន ៣២ រូបមកពីខេត្តស្វាយរៀង និងព្រៃវែងបានចូលរួមក្នុងការបណ្តុះបណ្តាល។ ការអប់រំ និងគណនេយ្យសារពើពន្ធដោយស្មើភាព ទទួលបានចំណាប់អារម្មណ៍យ៉ាងពិសេស។

**<u>មាតិកា</u>**

១. សេវាអ្នកជាប់ពន្ធ៖ ដោយ លោក ទេព្យចំរើន អនុប្រធានការិយាល័យនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

២. ការអប់រំអំពីសារពើពន្ធ៖ ដោយ លោកស្រី អ៊ិម៉ៃ

៣. សវនកម្មសារពើពន្ធនៅប្រទេសជប៉ុន៖ ដោយ លោកស្រី អ៊ិម៉ៃ

៤. គណនេយ្យមូលដ្ឋានសម្រាប់គ្រូបណ្តុះបណ្តាល៖ ដោយលោក លឹម ឌីលុច មន្ត្រី នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ

៥. ការពិគ្រោះយោបល់អំពីបច្ចេកវិទ្យាព័ត៌មាន៖ ដោយលោក ហេង ដារ៉ាវុធ ប្រធាន និងលោក រស់ សារាក់ អនុប្រធាន







ការត្រិះរិះពិចារណាគឺជាមធ្យោបាយដ៏ឆ្លាតវៃក្នុងការគ្រោង និងវិភាគបញ្ហារបស់រដ្ឋបាលសារពើពន្ធប្រកបដោយសុក្រិតភាព និងភាពស៊ីជម្រៅ

## ការធ្វើដំណើរទៅកាន់ប្រទេសជប៉ុនដ៏ត្រជាក់សម្រាប់ការបណ្តុះបណ្តាលនៅបរទេស

### ការបណ្តុះបណ្តាលនៅប្រទេសជប៉ុន វិធានការលើកកម្ពស់SAS

ថ្ងៃទី១២-១៩ ខែកុម្ភៈ

**ចំណុចគន្លឹះគឺការផ្ទេរដោយរលូនពីរបបមៅការសម្រាប់ការដាក់លិខិតប្រកាសពន្ធ។**

សិក្ខាកាមចាប់យកបាននូវសសរស្តម្ភចំនួនពីរគឺសេវាអ្នកជាប់ពន្ធ និងការអនុវត្តច្បាប់។ សិក្ខាកាមបាន ទៅទស្សនកិច្ចការិយាល័យពន្ធដារនៅក្នុងប្រទេសជប៉ុន ហើយបានអង្កេតសិក្ខាសាលារបស់អ្នកជាប់ពន្ធអំពី "*របៀបដាក់លិខិតប្រកាសពន្ធរបស់សាជីវកម្ម*" ដោយអនុវត្តរួមគ្នាជាមួយអង្គភាពឯកជន។ សិក្ខាសាលាចាំបាច់ត្រូវរៀបចំឡើងឲ្យបានទាន់ពេលវេលា ដោយផ្តោតជាសំខាន់លើប្រធានបទទោលមួយ ដោយមានសាស្ត្រាចារ្យដែលមានសមត្ថភាពចូលរួម។ ចំណុចសិក្សាដ៏សំខាន់មួយទៀតគឺការអប់រំអំពីសារពើពន្ធដើម្បីលើកទឹកចិត្តឲ្យអ្នកជាប់ពន្ធគោរពតាមដោយរួមទាំងអ្នកជាប់ពន្ធអនាគតផងដែរ។ ការអនុវត្តចាប់អ្នកជាប់ពន្ធដែលមិនគោរពតាមត្រូវធ្វើឡើងបន្ទាប់ពីផ្តល់សេវាកម្ម។



បទពិសោធន៍សិក្សាទាំងមូលមានអនុស្សាវរីយ៍មិនអាចបំភ្លេចបាន

## សេវាអ្នកជាប់ពន្ធគឺជាគន្លឹះឆ្ពោះទៅរកការលើកកម្ពស់ការអនុវត្តតាម

### ការបណ្តុះបណ្តាលនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី១៣-១៤ ខែកុម្ភៈ

**ការលើកកម្ពស់សេវាអ្នកជាប់ពន្ធមានសារសំខាន់បំផុតចំពោះការបង្កើតការអនុវត្តតាមរបស់អ្នកជាប់ពន្ធ។**

មន្ត្រីពន្ធដារសរុបចំនួន ៥៣រូបដែលបានចូលរួមក្នុងការបណ្តុះបណ្តាលនេះ គឺមកពីសាខាពន្ធដាខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ។ តម្រូវការរបស់មន្ត្រីទាំងនេះគឺដើម្បីសិក្សាអំពីគណនេយ្យ និង LOT ដើម្បីផ្តល់ការណែនាំដល់អ្នកជាប់ពន្ធ។

**<u>មាតិកា</u>**

១. ការអប់រំអំពីសារពើពន្ធ៖ ដោយ លោកស្រី អ៊ិម៉ែ

២. សវនកម្មសារពើពន្ធនៅប្រទេសជប៉ុន៖ ដោយ លោកស្រី អ៊ិម៉ែ

៣. គណនេយ្យមូលដ្ឋានសម្រាប់គ្រូបណ្តុះបណ្តាល៖ ដោយលោក ស៊ុន វុទ្ធី នាយក សាលាជាតិពន្ធដារ នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ

៤. សេវាអ្នកជាប់ពន្ធ៖ ដោយ លោក ទេព្យចំរើន អនុប្រធានការិយាល័យ នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

៥. ការពិគ្រោះយោបល់អំពីបច្ចេកវិទ្យាព័ត៌មាន៖ ដោយលោក ម៉េង មីនា ប្រធាន និងលោក សូ វិសុទ្ធ អនុប្រធានការិយាល័យ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន







ការធ្វើលំហាត់គណនេយ្យជាក្រុម

កម្រងសំណួរនៃការបណ្តុះបណ្តាលតាមតំបន់បានបញ្ជាក់អំពីភាពចាំបាច់នៃគណនេយ្យ និងចំណេះដឹងអំពី LOT ដែលត្រូវធ្វើការកែលម្អតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅសាលាពន្ធដារជាតិ

## បដារគឺជាសម្ភារៈទំនាក់ទំនងសាធារណៈ ដែលមានប្រសិទ្ធភាពថ្លៃចំណាយបំផុត!

### សិក្ខាសាលា

### សម្ភារៈទំនាក់ទំនងសាធារណៈ ដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ

### ថ្ងៃទី២៧ ខែកុម្ភៈ - ថ្ងៃទី០១ ខែមីនា

លោក Kumamoto មកពីការិយាល័យនៃ NTA និងលោកស្រី Mogawa មកពី NTC ត្រូវបានបញ្ជូន ឲ្យទៅធ្វើការពិភាក្សាអំពីការបង្កើតសម្ភារៈទំនាក់ទំនងសាធារណៈនៅអពដ។ សមាជិកក្រុមការងារទាំងអស់នៃសេវាអ្នកជាប់ពន្ធ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសិក្ខាសាលានេះ។ នៅប្រទេសជប៉ុន សម្ភារៈដែលទទួលលេខ១សម្រាប់អំឡុងពេលប្រកាសពន្ធ គឺ “បដារ” (ទទួលស្គាល់ 47.6%) បន្ទាប់មកគឺព័ត៌មាន ឬកម្មវិធីទូរទស្សន៍ (39.3%)។ សិក្ខាកាមបានបង្ហាញអំពីការយល់ដឹងដែលមានកម្រិតយ៉ាងខ្ពស់របស់ខ្លួនចំពោះសិក្ខាសាលានេះ ដូច្នេះគេរំពឹងថាសិក្ខាកាមទាំងនោះនឹងបង្កើតសម្ភារៈទំនាក់ទំនងសាធារណៈ ផ្សេងៗនៅក្នុងឆ្នាំនេះ។



## កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន

### តម្រូវការពិន្ទុភាសាអង់គ្លេសដែលត្រៀមសម្រាប់ការបើកឲ្យដាក់ពាក្យសុំនៅក្នុងខែមិថុនា!

មានកម្មវិធីអាហារូបករណ៍ថ្នាក់បញ្ចប់ការសិក្សានៅក្នុងប្រទេសជប៉ុនសម្រាប់មន្ត្រីពន្ធដារ។ កម្មវិធីនេះគឺជាកម្មវិធីចម្រុះមួយរបស់ជប៉ុន និងធនាគារពិភពលោក ហើយ NTA ជាអ្នកផ្តល់សាស្ត្រាចារ្យ។ សកលវិទ្យាល័យ Keio នៅទីក្រុងតូក្យូ ផ្តល់អាហារូបករណ៍សម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគោលនយោបាយ និងការគ្រប់គ្រងសារពើពន្ធ។

លក្ខណៈសម្បត្តិ៖

១. មន្ត្រីដែលមានបទពិសោធន៍បំពេញការងារយ៉ាងហោចណាស់រយៈពេល ៤ឆ្នាំផ្នែកគោលនយោបាយ និង រដ្ឋបាលសារពើពន្ធ

២. ពិន្ទុភាសាអង់គ្លេស៖ TOEFL 80/iBT ឬ IELTS 6.0

៣. អាយុចន្លោះពី ២៥ ទៅ ៤៥ ឆ្នាំ

បេក្ខជនត្រូវបំពេញលក្ខខណ្ឌតម្រូវទាំងអស់នេះ។ សូមទាក់ទងការិយាល័យ



# “ប្រាក់ចំណេញដុល” គឺជាសញ្ញានៃហានិភ័យរបស់អ្នកជាប់ពន្ធ

## ការបណ្តុះបណ្តាល

### ការអនុវត្តសវនកម្មសារពើពន្ធ

ថ្ងៃទី១១ -១៥ ខែមីនា

**ចំណេះធ្វើសម្រាប់សវនករសារពើពន្ធគឺ៖**

***គណនេយ្យ ច្បាប់ស្តីពីសារពើពន្ធ និងសុភវិនិច្ឆ័យ***

សិក្ខាកាមបានធ្វើកិច្ចពិភាក្សាជាក្រុមជាច្រើននៅក្នុងទម្រង់ជាសំណួរសាកល្បងដើម្បីស្វែងយល់ស៊ីជម្រៅអំពីការវិភាគហានិភ័យ។ ខ្លឹមសារនៃការបណ្តុះបណ្តាលនេះមានសារសំខាន់ណាស់ “របៀបវិភាគ” ហើយ “ឯកសារដែលចាំបាច់ត្រូវពិនិត្យដើម្បីបញ្ជាក់អំពីហានិភ័យដែលបានកំណត់” សាស្ត្រាចារ្យ Ikeda និង សាស្ត្រាចារ្យ Orikasa មកពី NTC បានរៀបចំការបណ្តុះបណ្តាលដែលផ្តោតជាចម្បងសម្រាប់មន្ត្រីពន្ធដារវ័យក្មេងនៅ អពដ និងសាខាពន្ធដារខណ្ឌ។ នៅទីបញ្ចប់ សាស្ត្រាចារ្យ Ikeda បានរាយការណ៍ជូនឯកឧត្តម គឹម សុភ័ក្ត្រ អំពីការបណ្តុះបណ្តាល នេះ និងបានដាក់សំណើចំនួនបី គឺសំណើសុំបន្តចែករំលែកចំណេះដឹងនៅក្នុងអង្គភាព ប្រើប្រាស់ជាក់ស្តែងនូវបច្ចេកទេសដែលបានសិក្សាអំពីការងារ និងសវនករសារពើពន្ធដែលត្រូវមានភាពបត់បែនក្នុងការដោះស្រាយបញ្ហា។





ការពិនិត្យមើលនិន្នាការនៃ “ប្រាក់ចំណេញដុល” និងការគិតអំពីជ្រុងផ្សេងទៀត

# មន្ត្រីអពដ ចាប់ផ្តើមចាប់យករចនាសម្ព័ន្ធពីរ៉ាមីត

## សិក្ខាសាលា

### ការត្រិះរិះពិចារណាទី ២

ថ្ងៃទី២៥ ខែមីនា - ថ្ងៃទី០៥ ខែមេសា

**មន្ត្រីពន្ធដារជាច្រើនពេលនេះ យល់អំពីទស្សនាទាន “*របៀបចាប់ត្រី*”**

វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងនៅក្នុងទីក្រុងភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុដោយមានប្រើប្រាស់ករណីជាក់ស្តែង ឧទាហរណ៍៖ បញ្ហាអំពី *ការមិនអនុវត្តតាម* និង*រយៈពេលដាក់លិខិតប្រកាសពន្ធដែលបានពន្យា* ។ល។ សាស្ត្រាចារ្យ Ishiguro បានសង្កត់ធ្ងន់អំពីទស្សនាទាន “បន្តផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា ហើយមិនត្រូវភ្លេចថាតើអ្វីជាគោលបំណងឡើយ”

ជំហានក្នុងការបង្កើតរចនាសម្ព័ន្ធពីរ៉ាមីត (PS)

Identify issue → Frame the issue → Find message → Check the logic





មន្ត្រីសរុបប្រមាណ ៣៥០ រូបបានរៀន “ការត្រិះរិះពិចារណា”






## កិច្ចខិតខំប្រឹងប្រែងរបស់អពដរួមស្របពេលនឹងមានកំណើនសកម្មភាពអាជីវកម្មបង្កើនប្រាក់ចំណូល

អពដ បន្តមានវិសាលភាពទូលំទូលាយក្នុងវិស័យសារព័ត៌មានដោយសារកំណើនប្រាក់ចំណូលពីមួយឆ្នាំទៅមួយឆ្នាំ។ នេះគឺដោយកិច្ចខិតខំប្រឹងប្រែងរបស់អពដ និងសាខាពន្ធដារ ព្រមទាំងដោយសារការបង្កើនសកម្មភាពអាជីវកម្ម។ អពដ សម្រេចបានកំណើនប្រាក់ចំណូលចំនួន ១១១% នៅឆ្នាំ២០១១ និងចំនួន ១២៥% នៅឆ្នាំ២០១២។ និន្នាការនេះកំពុងបន្តនៅក្នុងឆ្នាំ២០១៣ ដោយមានប្រាក់ចំណូលនៅខែកុម្ភៈ ចំនួន ១២៨% ក្នុងរយៈពេលដូចគ្នានឹងឆ្នាំ២០១២។ ទិន្នផលធំបំផុតនៅក្នុងឆ្នាំ២០១២ គឺបានមកពីការប្រមូលពន្ធលើអចលនទ្រព្យ (១៥៤%) បន្ទាប់ពីពន្ធលើប្រាក់ចំណេញរបស់សហគ្រាសឯកជន (១៤១%)។

គម្រោងនេះ នឹងបន្តកសាងសមត្ថភាពរបស់អាជ្ញាធរពន្ធដារ និងសកម្មភាពស្ថាបនាកម្មដើម្បីលើកកម្ពស់ការគោរពតាមរបស់អ្នកជាប់ពន្ធ។




## កិច្ចសហប្រតិបត្តិការល្អរបស់អ្នកជាប់ពន្ធអំពីលទ្ធផលស្ទង់មតិ

### ធ្វើការស្ទង់មតិអំពីការពេញចិត្តរបស់អ្នកជាប់ពន្ធ

ការស្ទង់មតិបិទអំពីការពេញចិត្តរបស់អ្នកជាប់ពន្ធត្រូវបានផ្តួចផ្តើមដោយជំនាញការចៃការ និងប្រមូលបានលទ្ធផលចំនួន ១,៤៦៣។ អ្នកស្ទង់មតិ បានធ្វើទស្សនកិច្ចនៅសាខាពន្ធដារខេត្តចំនួន ៤ គឺខេត្តកំពង់ចាម បាត់ដំបង សៀមរាប និងព្រះសីហនុ នៅចន្លោះថ្ងៃទី១៣ ទៅ ១៥ ខែមីនា។ ជាមួយគ្នានេះដែរ ការស្ទង់មតិដូចគ្នានេះត្រូវបានធ្វើឡើងនៅអពដ សាខាពន្ធដារខណ្ឌដូនពេញ ខណ្ឌចំការមន និងខណ្ឌទួលគោកពីថ្ងៃទី ២៧ ដល់ ២៩ ខែមីនា។ ពេលនេះ លទ្ធផលទាំងនេះកំពុងធ្វើការវិភាគ ហើយយើងមានបំណងបោះផ្សាយរបាយការណ៍នេះនៅក្នុងខែសីហា ឆ្នាំ២០១៣ខាងមុខនេះ។



គម្រោងនេះនឹងបន្តពង្រឹងសមត្ថភាពរបស់អពដដើម្បីបង្កើនចំណូល។

## ព្រឹត្តិការណ៍បច្ចុប្បន្ន ...

### ព្រឹត្តិការណ៍សំខាន់ៗ

**ថ្ងៃទី០៣-០៤ ខែឧសភា**
ទស្សនកិច្ចសិក្សាទៅមជ្ឈមណ្ឌលប្រតិបត្តិការទិន្នន័យ និងមជ្ឈមណ្ឌលផ្តល់សេវាកម្មប្រទេសសិង្ហបុរី

**ថ្ងៃទី០៦-១០ ខែឧសភា**
ការបណ្តុះបណ្តាល៖ បច្ចេកទេសសវនកម្មសារពើពន្ធដោយមិនបានពិនិត្យឯកសារនៅខេត្តបាត់ដំបង និងសាលាពន្ធដារជាតិ ដែលជាកិច្ចសហការរបស់លោក Takeuchi ទីប្រឹក្សាក្រុមប្រឹក្សាចំណូលផ្ទៃក្នុងប្រទេសម៉ាឡេស៊ី និងលោកស្រី អ៊ិម៉ៃ

**ថ្ងៃទី០៣-០៧ ខែមិថុនា**
កម្មវិធីបណ្តុះបណ្តាលនៅក្នុងប្រទេសជប៉ុន៖ វិធានការដើម្បីជំរុញ SAS៖ សេវាអ្នកជាប់ពន្ធ

### ការងារកំពុងដំណើរការ

**អនុក្រុមអប់រំអំពីសារពើពន្ធ**
ធ្វើសេចក្តីព្រាងបដារ និងខិតប័ណ្ណអប់រំអំពីពន្ធដារ និងសញ្ញារយៈពេលដាក់លិខិតប្រកាសពន្ធ។ គោលបំណងបង្កើតសញ្ញា និងផ្ទាំងបង្ហាញនៅអពដ និងគ្រប់សាខាពន្ធដារទាំងអស់នៅក្នុងខែឧសភា

**សំណួរដែលមានជាញឹកញាប់ - អនុក្រុម**
ធ្វើសេចក្តីព្រាងសំណួរ-ចម្លើយសម្រាប់ពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម ពន្ធប៉ាតង់ និងពន្ធលើអចលនទ្រព្យ។ គ្រប់សាខាពន្ធដារទាំងអស់ត្រូវបានលើកទឹកចិត្តអោយដាក់សំណួរ-ចម្លើយបន្ថែមជូនអពដ។

**ក្រុមការងារសវនកម្មសារពើពន្ធ**
ទម្រង់សម្រាប់សៀវភៅករណីសវនកម្មត្រូវបានអនុម័តដោយឯកឧត្តមអគ្គនាយក។ សមាជិកក្រុមការងារនឹងចែករំលែកបទពិសោធន៍គ្នា។

JICA HP

http://www.jica.go.jp/english/index.html


ការិយាល័យគម្រោងចៃការ(JICA) នៅអពដ

អគ្គនាយកដ្ឋានពន្ធដារ

(បន្ទប់៦០១)

ទូរស័ព្ទ 023 689 1617

ទូរសារ 023 689 1617

អ៊ីមែល: jicaproject_gdt@yahoo.com



បោះពុម្ពផ្សាយដោយ៖ អ៊ិម៉ៃ តាកាកុ


សម្រាប់អគ្គនាយកដ្ឋានពន្ធដារ និងប្រជាជនកម្ពុជា

គម្រោងនឹងបោះពុម្ពផ្សាយកម្រងព័ត៌មាននេះ ដើម្បីជូនដំណឹងលោកអ្នកអំពីសកម្មភាព និងដំណើរការរបស់យើង។ ដោយសារយើងទាំងអស់គ្នា មានគោលបំណងដូចគ្នា យើងសូមលើកទឹកចិត្តអោយលោកអ្នកចូលរួមទាំងអស់គ្នា។ គម្រោងប្តេជ្ញាឆ្លើយតបចំពោះមតិយោបល់និងសំណើរបស់លោកអ្នក។ ដូច្នេះសូមប្រាប់យើងអំពីអ្វីដែលលោកអ្នកគិត។